00211363

**Declassified to Public**
**06 September 2012**

លេខ/No: D25/15/3

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ORIGINAL DOCUMENT/DOCUMENT ORIGINAL
(Date of receipt/Date de reception): 11 / 08 / 2008
(Time/Heure): 12:35
Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

### ជម្រាបមក

**ឈ្មោះ៖ សួន សៀង SUON Sieng**

**អាស័យដ្ឋាន៖ មជ្ឈមណ្ឌលឯកសារកម្ពុជា** ផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ ខណ្ឌចំការមន រាជធានីភ្នំពេញ

**ថ្ងៃទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយក្រឡាបញ្ជីរបស់សហចៅក្រុមស៊ើ**

**សំណុំរឿងព្រហ្មទណ្ឌលេខ៖** ០០១/១៨-០៧-២០០៧-ECCC-OCIJ/D25/15

CERTIFIED COPY/COPIE CERTIFIÉE CONFORME
(Certified Date/Date de certification): 11 / AUG / 2008
Case File Officer/L'agent chargé du dossier: C.A. FRY

**កម្មវត្ថុ៖ ស្ថានភាពនៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ទំរង់បែបបទសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក-លោកស្រី ត្រូវបានទទួលដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ហើយ តាមការណែនាំរបស់លោកសហចៅក្រមស៊ើបអង្កេត ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ដូចបានបញ្ជាក់ខាងលើខាងលើ ។ ដូច្នេះ លើកលែងតែមានសេចក្តីសម្រេចផ្លាស់ប្តូរនៅពេលក្រោយរបស់សហចៅក្រមស៊ើបអង្កេត (សូមអានកឋាខ័ណ្ឌទី ២) លោក-លោកស្រី នៅពេលនេះ ត្រូវបានចាត់ទុកជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណើរការស៊ើបអង្កេតរបស់តុលាការទាក់ទិននឹងរឿងក្តីនេះ។

សូមរំលឹកថា នៅគ្រប់ពេលនៃដំណើរការស៊ើបអង្កេតរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតអាចធ្វើសេចក្តីសម្រេចផ្លូវការមួយទាក់ទិននឹងពាក្យសុំរបស់លោក-លោកស្រី ដែលអាចជាការសម្រេចយល់ព្រម ឬបដិសេធ ប្រសិនបើសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា លោក-លោកស្រី

មិនមែនជាជនរងគ្រោះ ឬថាលក្ខណៈវិនិច្ឆ័យទាំងឡាយដែលកំណត់ដោយវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មិនត្រូវបានបំពេញ។ សេចក្តីសម្រេចបែបនេះ គឺបើកឲ្យធ្វើបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះបាន។

លោក-លោកស្រី ក៏ត្រូវដឹងផងដែរថា តាមរយៈការចូលរួមក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី លោក-លោកស្រី អាចដឹងអំពីព័ត៌មានសម្ងាត់នានាដែលមាននៅក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ។ មានតែចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ប៉ុណ្ណោះ ដែលអាចសម្រេចផ្តល់ព័ត៌មានទាំងនោះជាសាធារណៈ។ លោក-លោកស្រី មានកាតព្វកិច្ចរក្សាការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ ដោយមិនត្រូវលាតត្រដាងព័ត៌មានសម្ងាត់ទាំងនេះឡើយ លើកលែងតែព័ត៌មានផ្ទាល់ខ្លួនណាដែលលោក-លោកស្រីបានផ្តល់ជូនចៅក្រមនៅក្នុងពាក្យសុំរបស់លោក-លោកស្រី។

ប្រសិនលោក-លោកស្រី ត្រូវការការណែនាំបន្ថែម ទាក់ទិននឹងការចូលរួមរបស់លោក-លោកស្រី នៅក្នុងនីតិវិធីតុលាការ សូមធ្វើទំនាក់ទំនងមកកាន់អង្គភាពគាំពារជនរងគ្រោះ។ វិធាន និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក. អាចពិគ្រោះ និងថតចម្លងទុកបានពីគេហទំព័រនៃអង្គភាពគាំពារជនរងគ្រោះ (www.eccc.gov.kh)។

សូមលោក-លោកស្រី ទទួលនូវការរាប់អានអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៦ ខែសីហា ឆ្នាំ ២០០៨

ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត

LY Chantola លី ច័ន្ទតុលា

 